អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១១

# <u>សេចក្តីប្រកាសព័ត៌មាន</u>

## ដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ

បន្ទាប់ពីទទួលបានការតែងតាំងនៅថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១១ សហចៅក្រមស៊ើបអង្កេតអន្តរជាតិនៃ អ.វ.ត.ក បានដំណើរការកិច្ចស៊ើបសួរនៅក្នុងសំណុំរឿង ០០៣ និង ០០៤ ដោយមានការរំពឹងថា សេចក្តីថ្លែងការណ៍កន្លងមកដែលបានធ្វើឡើងដោយនាយករដ្ឋមន្ត្រីកម្ពុជា ក្នុងពេលជួបជាមួយអគ្គលេខាធិការដែលថា "សំណុំរឿងទាំងនេះនឹងមិនត្រូវបានអនុញ្ញាត" មិនបានឆ្លុះបញ្ចាំងអំពីគោលនយោបាយទូទៅរបស់រដ្ឋាភិបាលទេ។

ទោះជាយ៉ាងណាក្តី នៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១១ រដ្ឋមន្ត្រីក្រសួងព័ត៌មានកម្ពុជាបានថ្លែងថា "បើពួកគេចង់ស៊ើបអង្កេតសំណុំរឿង ០០៣ និង ០០៤ ពួកគេត្រូវវេចឥវ៉ាន់ចេញទៅ"។ ទោះបីសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានផ្តួចផ្តើមកិច្ចដំណើរការនីតិវិធីលើករណីប្រមាថតុលាការប្រឆាំងនឹងរូបគាត់ ហើយរំពឹងថាចំណុចនេះក្លាយជាការព្រមានដល់មន្ត្រីរដ្ឋាភិបាលផ្សេងទៀតក៏ដោយ តែមានការរាយការណ៍ថាកាលពីសប្តាហ៍មុន រដ្ឋមន្ត្រីក្រសួងព័ត៌មានបានថ្លែងថា "អំពីបញ្ហាចាប់ខ្លួនមេដឹកនាំខ្មែរក្រហមបន្ថែមទៀតនេះជាបញ្ហារបស់កម្ពុជា...។ បញ្ហានេះត្រូវតែសម្រេចដោយកម្ពុជា"។ (កាសែត Cambodia Daily ចុះផ្សាយថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១១)។

ទោះបីសហចៅក្រមស៊ើបអង្កេតអន្តរជាតិ នឹងមិនបណ្តោយខ្លួនគាត់ឲ្យស្ថិតក្រោមឥទ្ធិពលនៃសេចក្តីថ្លែងការណ៍ទាំងនេះក្តី ក៏នាំឲ្យមានភាពសង្ស័យអំពីសមត្ថភាពរបស់គាត់ក្នុងតតាំងនឹងសម្ពាធពីមន្ត្រីរដ្ឋាភិបាល និងការបំពេញភារកិច្ចដោយឯករាជ្យ ហើយប្រការនេះនឹងនាំឲ្យមានភាពសង្ស័យពីសុចរិតភាពនៃកិច្ចដំណើរការនៅក្នុងសំណុំរឿង ០០៣ និង ០០៤ ទាំងមូល។



Original EN: 01699219-01699219

ដោយសារតែមានការធ្វើសេចក្តីថ្លែងការណ៍បែបនេះម្តងហើយម្តងទៀត ដែលនឹងត្រូវបានប្រមើលមើលថាជាការប៉ុនប៉ងជ្រៀតជ្រែកពីសំណាក់មន្ត្រីរដ្ឋាភិបាលទៅក្នុងសំណុំរឿង ០០៣ និង ០០៤ នោះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានដាក់លិខិតលាលែងពីមុខតំណែងជូនអគ្គលេខាធិការ ចាប់ពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១១ តទៅ។